ឧបសោសង្ហា

# កម្លាំងនិងការចេះដឹងខ្មែរ



## មាតិការឿង


**បុព្វកថា**......................................................................................2

**ពុទ្ធសាសនា**...................................................................................3

**ពុទ្ធសាសនានៅស្រុកខ្មែរ**..............................................8

**ទស្សនៈវិជ្ជា**...................................................................................9

**ទស្សនវិជ្ជានៅស្រុកខ្មែរ**...............................................12

**លទ្ធិប្រជាធិបតេយ្យ**.........................................................15

**លទ្ធិប្រជាធិបតេយ្យ នៅ ស្រុកខ្មែរ**............................17

# ពុទ្ធសាសនា ទស្សនៈវិជ្ជា និង លទ្ធិប្រជាធិបតេយ្យ នៅស្រុកខ្មែរ

## បុព្វកថា

ចំពោះ អ្នកឆ្វេងនិយមខ្មែរ តែងតែ មាន យោបល់ ថា ពុទ្ធសាសនា ជា ឧបសគ្គ នៃ ការលើកដំកើង (promotion) នៃ លទ្ធិប្រជាធិបតេយ្យ នៅ ស្រុកខ្មែរ ដែល ជា គំនិត ជា ទូទៅ នៅក្នុង មជ្ឈដ្ឋាន ពួក អ្នកជឿនលឿននិយម ផ្ដុំ ជា វណ្ណៈបញ្ញវន្ត (intelligentsia) បក្ស លទ្ធិកុម្មុយនិស្ត នៅ មស្ទីមប្រទេស នៅ ក្នុង សតវត្ស ទី២០ ដែល ទុក សាសនា ជា អាភៀន នៃ សង្គមមនុស្ស។

ដើម្បី ទុកជា យោងគំនិត ក្នុងការពិនិត្យ គំនិតនេះ គួរយើងលើកជាសង្ខេប យក ការវិវត្តន៍ នៃចំណេះ នៃមនុស្សជាតិ សំរាប់ ឲបាន ស្គាល់ ទីតាំង នៃពន្លឺចំណេះសាសនា ក្នុង ចំណោម ពន្លឺចំណេះ ដទៃទៀត មាន នៅ ក្នុង មនុស្សជាតិ។ ដំបូងទី មនុស្សលោក រស់ នៅ ក្នុងឥទ្ធិពល ធម្មជាតិ ទុក ជា ច្បាប់ សំរាប់ គ្រប់គ្រង ការរស់នៅ រៀងរាល់ថ្ងៃ របស់ មនុស្សលោក។ ឥទ្ធពលនេះ ត្រូវបាន មនុស្សខ្លះ ឆ្លៀត យក ធ្វើ ជា ចំណេះ អាថ៌កំបាំង (mystique) របស់ខ្លួន ព្រោះខ្លួន ស្គាល់បានខ្លះ តាមការសង្កេត នូវ បាតុភូត នៃធម្មជាតិ ហើយបង្កើត នូវជំនឿ អាថ៌កំបាំង សំរាប់ឲខ្លួន ក្លាយជាមនុស្ស មានឥទ្ធ លើ មនុស្សដទៃទៀត ដោយសារ គេទទួលស្គាល់ខ្លួន ថាជា អ្នក មាន អភិញ្ញា (pouvoir spirituel)។ មនុស្សទាំងនោះ គឺ ជា គ្រូធ្មប់ គ្រូមរ (គ្រូខ្មោច) ចេះ ហៅព្រលឹងខ្មោច ចេះ មន្ត សូត្រ រំដោះគ្រោះ ធ្វើ ជា គ្រូព្យាបាលជម្ងឺ ជា គ្រូទាយ អំពីអនាគត ដែល សុទ្ធ ជា ចំណេះ មានប្រយោជន៍ សំរាប់ការរស់នៅ របស់ មនុស្ស នៅក្នុងសម័យនោះ ហើយនៅ មាន ចំហាយ រហូត មក ដល់ បច្ចុប្បន្ន នេះ។ អបិយជំនឿ នេះ ត្រូវ ជំនឿលើសាសនា បន្សាប បន្តិចម្ដងៗ ព្រោះ វា ជា ជំនឿវិវិធ មាននៅក្នុង និគមជន មនុស្ស តូចៗ រៀងៗខ្លួន គ្មាន ក្បួនតែមួយ គ្មាន លទ្ធិជំនឿ ពិតប្រាកដ។ ចំណែក ចំណេះ របស់សាសនា ប្រកាសថា មានអាទិទេព ជា អ្នកបង្កើតលោកា ដែលជាបិតា នៃធម្មជាតិ ដែលមាន សត្វលោក ជា សមាសភាព ក្នុងចំណោម សមាសភាព ដទៃទៀត។ ដូច្នេះ បើជាការ បង្កើត ត្រូវ មាន អភិក្រម (processus) ច្បាស់លាស់ ដែលមាន ចែងច្បាស់លាស់ នៅ ក្នុង និតីក្រម (procédure) មួយ ដែលគេទុក ជា ទិដ្ឋិ (dogme) ដែល ត្រូវតែជឿវា ជា ដាច់ខាត។ តែជំនឿ សាសនា នៅតែជាជំនឿមួយ មានអាថ៌កំបាំង ដូចជំនឿដើមនៃ មនុស្សលោក នោះ ដែរ គឺថា នៅ តែចែក លោកា ជា ច្រើនលោក មាន៖ លោក នៃ អាទិទេព និង ពួក ទេវតា, លោកកីយ (លោកនៃមនុស្សលោក) និង លោក នៃ ព្រលឹង





ហើយ អនុមាន ថា អត្ថភាពនេះ ជាការពិតរបស់ខ្លួន លើក ឧទាហរណ៍ ធ្វើការបញ្ជាក់ ដោយ បង្ខំ ឲ ជឿ ថា ផែនដី មាន រូបរៀង សំប៉ែត។ តែ ក្រោយមក ជំនឿសាសនា មាន ការប៉ះទង្គិច ជាមួយ ចំណេះ ថ្មី មួយ ទៀត ជា ពិសេស នៅប្រទេស គ្រេញ ដែលគេ ទុកជា ប្រភព នៃ អារ្យធម៌ មស្ចឹមប្រទេស គឺ ចំណេះ ទស្សនៈវិជ្ជា ដែល ជា ចំណេះមួយ ធ្វើ ការស្រាវជ្រាវ បែប បរមវិជ្ជា (ការស្រាវជ្រាវ ដែល ស្របតាម វិចារណញ្ញាណ ដើម្បី រក ការចេះដឹង អំពី មនុស្សលោក, ធម្មជាតិ, អាទិទេព, វត្ថុធាតុ ។ល។)។ ជា ចំណេះ កើត ចេញ ពី ការពិចារណា តាម ការជជែក វែកញែក របស់ ពួក ទស្សនៈវិទូ រកការពិតដែល ចំណេះសាសនា គេ ទុក ជា ការពិត ដាច់ខាត របស់គេ។ ចំណេះទាំងពីរនេះ ឈមមុខ តតាំង គ្នា ដោយ អង់អាច មាន រហូត ហ៊ាន ប្តូរ ជីវិត ដូច លោក Socrate ជាទស្សនៈវិទូមួយរូប សុខចិត្ត ស្លាប់ ដោយ គាត់ មិន សុខចិត្ត បោះបង់ ការយល់ឃើញ របស់ គាត់ ដែល ជាគំនិត ខុសពី ជំនឿសាសនា។ ទីបញ្ចប់ ការប្រឈរមុខ ដាក់គ្នានេះ គ្មាន អ្នកឈ្នះ គ្មានអ្នកចាញ់ ព្រោះ ជំនឿសាសនា នៅ តែ មាន ឥទ្ធិពល ជានិច្ច ទៅ លើ ប្រជាជន សាមញ្ញ ឯ ចំណែក ទស្សនៈវិជ្ជា វិញ វាយ ដណ្តើមបាន មជ្ឈដ្ឋាន អ្នកចេះដឹង រហូត មានឥទ្ធិពល ទៅលើ ព្រះមហាក្សត្រ មានពន្លឺបញ្ញា ជាច្រើន ដែល ក្លាយទៅ ជា អ្នកការពារខ្លួន ពី ការបំពាន ពី សំណាក់ អាជ្ញាធរ សាសនា ជា ពិសេស អាជ្ញាធរ ស ម្តេច ប៉ាប តែ ម្តង។ ក្រោយបន្តិច មកទៀត មាន ចំណេះ វិទ្យាស្ស្រ្ត ដែល ជាចំណេះ អាច បង្ហាញ នូវ ការពិត ជាក់ស្តែង អំពី ធាតុភូត នៃ ធម្មជាតិ តាម របៀបសិក្សា ដោយ យក វិធី ពិសោធ មករក ការពិត ហើយ អាច ពន្យល់ វែកញែក យ៉ាងជាក់ លាក់ ពី លទ្ធផល នៃ ការពិសោធ របស់ខ្លួន។ ចំណេះថ្មីនេះ ហូរ ជ្រួតជ្រាប ពេញ មហាវិទ្យាល័យ ទាក់ទាញចិត្ត យុវជន មកសិក្សា បង្កើត បាន ជា ចំណេះ សាកល ដែល ជា ចលករ នៃ ការរីកចំរើន របស់ ពិភពលោក បច្ចុប្បន្ន នេះ។ តែ ចំណេះនេះ ក៏ មិនមែន ទុក ជា អ្នកឈ្នះ ដាច់ខាត លើ ចំណេះ សាសនា ទស្សនៈវិជ្ជា នោះដែរ ព្រោះ ខ្លួន នៅ មិនទាន់ អាច ទម្លុះទម្លាយ ឲ អស់បាន នូវ អ្វី ដែល ជា អាថ៌កំបាំង នៃ ព្រលឹង របស់ មនុស្សលោក។ តែគេ ដឹងដែរ ថា ចំណេះ វិទ្យាស្ស្រ្ត ក៏មាន លក្ខណៈ វា ជា ចំណេះ កសាងផង ជា ចំណេះ បំផ្លាញផង ដូចយ៉ាង ការរកឃើញ រូបមន្ត ធ្វើ គ្រាប់បែក ប៉ារាមាណូ ជា ឧទាហរណ៍ស្រាប់ ដូច ជា ពាក្យ ប្រៀនប្រដៅ មួយ ចារទុក ថា «វិទ្យាស្ស្រ្ត គ្មាន សតិសម្បជញ្ញៈ គឺគ្រាន់តែ ជា សេចក្តីវិនាស មួយ តែប៉ុណ្ណោះ»។

## ពុទ្ធសាសនា

ជាទូទៅ ពុទ្ធសាសនា ជា វិធី មួយ សំរាប់ រំដោះ មនុស្ស ឲ ចេញផុត ពី រាគៈ តត ទីបញ្ចប់ ដែល ព្រះសម្ពុទ្ធ ទុក ជា ប្រភព នៃ សេចក្តីវេទនា របស់ មនុស្សលោក នៅក្នុង លោកិយ នេះ។ គឺជា សង្ខារ (formation) ចិត្ត មនុស្ស ឲស្គាល់ច្បាស់ នូវធាតុ នៃទុក្ខ របស់ខ្លួន មាននៅក្នុង ធាតុមនុស្សលោក ជា រូបខន្ធ (agrégat de la matière), វេទនា (agrégat des sensations), សញ្ញា (agrégat des perceptions)។ ដើម្បី រំសាយចេញ ទុក្ខ នេះ មនុស្ស ត្រូវ ប្រើ សង្ខារ (agrégat des formations) និង វិញ្ញាណ (agrégat de la connaissance ou conscience) ដែល មានដែរ នៅក្នុង ធាតុ មនុស្សលោក មកធ្វើ ជា ផ្លូវរំដោះខ្លួន ចេញពីទុក្ខ។ ត្រូវដឹងថា អ្វីៗ ក៏មាន នៅ ក្នុង ធាតុមនុស្សលោក ទាំងអស់ ដូច្នេះហើយបាន ជា ព្រះសម្ពុទ្ធ ថ្លែងថា «ខ្លួនទីពឹងខ្លួន» ព្រោះ អ្វី ក៏ ដោយ ក៏ មនុស្សលោក អាចរក ឃើញ ដោយ ខ្លួនឯង បើ ខ្លួន ខំរក ដោយ ការបំពេញព្យាយាម៌ (ប្រធានានុយោគ) រក វា ឲ ឃើញ។ ផ្លូវ គឺ ការធ្វើ សមាធិក សិក្សា ពិចារណា ដើម្បី ឲរួចចាកទុក្ខ (មោក្សធម៌) តាម វិធីទូន្មានចិត្ត (យោគៈ), តាម វិធីទូន្មានកាយ (តបធម៌) ដែល ជា ទុក្កកិរិយា (ការធ្វើបាន ដោយ ក្រៃលែង) ហេតុនេះ ត្រូវ មាន សេចក្តី តាំងចិត្ត (សមុទាចារ) អោយទូលាយ (វិត្ថារ) តែ ជា ចិត្តខ្ពស់ (មនោសារៈ) ដើម្បី រំដោះ ចិត្ត ពី កិលេស គ្រប់បែបយ៉ាង ដែល ជា ជង្រុក នៃទុក្ខ របស់ មនុស្សលោក។ បរិនិព្វាននោះឯង គឺ ទីដៅ នៃការតាំងចិត្ត នៅក្នុង សក្កាយទិដ្ឋិ (Idée en soi) ជា វិរិយៈ (effort) រកសេចក្តីសុខ តាមធម៌ព្រះសម្ពុទ្ធ ដោយខ្លួនឯង ដើម្បីខ្លួនឯង មិនដូច អ្នកខ្លះ យល់ឃើញ ថា ជាបាតប័ត្រ (résignation) បោះបង់ សទ្ធិជាមនុស្សលោក ដើម្បី រស់ ជា មនុស្ស អកម្ម នៅ ក្នុងសង្គមមនុស្សលោក នោះឡើយ។ ដូច្នេះ បរិនិព្វាន មិន មែនជា ការបោះបង់ នៃការរស់នៅ ជា មនុស្សលោក នោះឡើយ តែ ជា ឧបាទាន (processus du devenir) ជា មនុស្ស មាន ធម៌ ហើយ ធម៌ នេះ ជួយជា ប្រទីប ទ្រោលបំភ្លឺ ជា តម្រាយ នៃ ជីវិត រស់នៅ ជា មនុស្សលោក។

នៅក្នុងទ្រឹស្តី ព្រះពុទ្ធសាសនា ន័យនៃជំនឿ គឺ អភិសោធន៍ (purification) និង ជវនៈ (élan)៖

**អភិសោធន៍** ជា មាគ៌ា សំរាប់ រំលាយ ឧបសគ្គ ហើយ នៅ ពេលណា វិញ្ញាណ (esprit) រំដោះ ខ្លួន ចេញបាន ពី ឧបសគ្គ រួចហើយ ទៅជា ថ្លាឆ្វង់ ហើយ បរិសុទ្ធ។ **ជវនៈ** ជា សន្ទុះ របស់ វិញ្ញាណ គឺ ដោះលែង នូវថាមពល ដើម្បី ផ្ញើសញ្ជ័យ (វាយដណ្តើម) យកបាន ខ្សែចរន្តទឹក ដែលហូរ ទៅរកការសង្គ្រោះ ដែលជាផ្លូវចុងក្រោយបង្អស់ នៃជីវិតមនុស្សលោក លែងវិលត្រឡប់ មករស់នៅ ក្នុងឋាន លោកិយ ដូច ជា ជីវិតចុងក្រោយបង្អស់ របស់ព្រះសម្ពុទ្ធ ដែល ព្រះអង្គ ដើរដល់ទីដៅ នៃបំណង គឺ បរិនិព្វាន នោះឯង។ ដូច្នេះ ជំនឿ ជា ភក្តិមាគ៌ា (salutation) រំដោះ ជីវិត ដែលបានបំពេញ សីលធម៌ (vertu) ជា មនុស្សល្អ មានចិត្តថ្លាឆ្វង់ បោះបង់ នូវជីវិត មនុស្សលោក តាម បារមីធម៌ (state of

perfection) ដើម្បី ជា យាន ភេត្រា សំរាប់ជិះឆ្លង ទៅ ឋាននិព្វាន ដែល ជា ឋានគ្មាន ឈ្មោះ គ្មាន រូប។ ឈ្មោះ-រូប នេះឯង ជា អត្តភាពនៃ មនុស្សលោក នៅ ក្នុង សភាវធម៌ (លោកនេះជាទុក្ខ) ដែល កំពុង រស់ នៅក្នុង កម្មផល។ កម្មផល ជា សញ្ញាណ នៃអតីតជាតិ និង ជាតិ ដែល កំពុងរស់ ក្នុង វាលវែង វដ្តសង្សារ នៃ មនុស្សលោក។ ទុក្ខនេះ មិនមែន សំដៅទៅលើ ត្រឹមតែ កង្វះ នៃ សម្ភារៈ ជា ភាពសម្បូណ៍ធនធាន ដែល ជា ទុក្ខតាម ផ្លូវកាយ គឺ សំដៅ ទៅ លើ ដែរ នូវ ទុក្ខ តាមផ្លូវចិត្ត កើត ពី អវិជ្ជា តណ្ហា អនិច្ចំ។ អតីតជាតិ ជា កម្ម (អំពើ) ដែល បាន ប្រព្រឹត្តិ រួចមកហើយ បង្កើត បាន ជាផល សំរាប់ ជាតិកំណើតថ្មី អាច ជាផលល្អ អាច ជា ផលអាក្រក់ មាននៅក្នុង សភាវធម៌ ជា អនិច្ចំផល ដូច្នេះ កម្មផល មិនមែន ជា វាសនា នៅនឹងថ្កល់ សំរាប់ ជាតិកំណើត ដែល កំពុង រស់នៅ នោះឡើយ។ កម្មផល ជា ចលនា អចិន្ត្រៃយ៍ ប្តូរ នៅក្នុង បារមីធម៌ (state of perfection)។ ការប្តូរ អាច មាន កើត ឡើង នៅ ក្នុង ជាតិ ដែល បុគ្គលម្នាក់ កំពុងរស់នៅ មាន ជា ឧទាហរណ៍ កើត ជា កូន អ្នកក្រ បើ មាន ការតស៊ូ ក្នុង ជីវិត តាម ការខំរៀនសូត្រ អាច ប្តូរ ស្ថានភាព មាន ពីកំណើត បាន ព្រោះ ក្លាយ ទៅជា អ្នកមានចំណេះ ដែល ជា ធនធាន សំរាប់ រស់នៅ ប្រកប ដោយ សេចក្តីសុខ បើ រស់នៅ លើ ភក្តិមាគ៌ា (salutation) បន្ត សាង កុសលល្អ ដើម្បី រំដោះខ្លួន ចេញពី លោកីយ ជា ទុក្ខ នៃ មនុស្សលោក។ កម្មផល ជា វិរយៈ (ការតស៊ូប្រកប ដោយ ថាមពល) អចិន្ត្រៃយ៍ សំរាប់ ស្វែង រក វិក្រិតភាព ក្នុង ការរស់នៅ របស់ មនុស្ស ដែល មនុស្សម្នាក់ៗ មាន សក្តានុពល អាច ធ្វើបាន ព្រោះខ្លួន រស់ នៅក្នុង បារមីធម៌។ សក្តានុពល នៃ មនុស្សលោក នេះ គឺៈ **មេត្តា** (ការចេះប្រមាណ) **សេចក្តីក្លាហ៊ាន** និង **ការប្រុងប្រយ័ត្ន** នៅក្នុង ជីវិត រស់នៅ។

ដូច យើង បានជំរាប ខាងលើ រួចមកហើយ ថា ពុទ្ធសាសនា ក៍ ជា ចំណេះ មួយ រស់ នៅក្នុង វិវត្តន៍ នៃ ចំណេះ ឯទៀតៗ មាន ចំណេះ អាថ៌កំបាំង ចំណេះ ទស្សនៈវិជ្ជា និង ចំណេះ វិទ្យាស្ស្រង្ស។ តែនៅ អាស៊ី ចំណេះ ទាំងនោះ នៅ ក្នុង ការវិវត្តន៍ របស់ ខ្លួន មិន មាន ទទាស់ទទែង ជា ទំនាស់ទ្រឹស្តី ដូច នៅ អ៊ឺរុប នោះឡើយ។ នៅ តណ្ហា ចំណេះ និមួយៗ មាន កន្លែង ទន្ឋៈ (solide) របស់ខ្លួន រៀងៗខ្លួន នៅ ក្នុង ជំនឿ នៃ មនុស្សលោក។ នៅប្រទេសចិន ទ្រឹស្តី កុងជឿ (Confucius) ដែលគេ អាចទុក បាន ជា ទស្សនៈវិជ្ជា គ្មាន ទំនាស់ ជាមួយ នឹង ពុទ្ធសាសនា នោះដែរ។ ឯចំណែក វិទ្យាស្ស្រង្ស វិញ មានការរីកចំរើន របស់ខ្លួន ជួនកាល នៅ ក្រោម ម្លប់ នៃ សាសនា ថែមទៀតផង។ បាតុភូត នេះ អាច មានបាន នៅអាស៊ី ព្រោះ សាសនា មាន លក្ខណៈ មិនត្រឹម តែ ជា ជំនឿ ប៉ុណ្ណោះទេ គឺ វា ជា របបជីវិត (mode de vie) របស់ ប្រជាជន តែម្តង ដូច្នេះ គ្រប់ ចំណេះ ដទៃទៀត ឲតែមាន លក្ខណៈ ជា ប្រយោជន៍ ដល់ការរស់នៅ តែងតែ មាន កន្លែងខ្លួន ជា និច្ច នៅក្នុង របប ជីវិត នៃ សង្គម ព្រោះ វា ជា សុភមង្គល រួមគ្នា (utilitarisme)។





ករណី ពុទ្ធសាសនា រឹតតែ ពិសេស ទៅទៀត ព្រោះ ជា ទ្រឹស្ដី អហិង្ស មិនយក គំនិត ណា មួយ ជា សត្រូវ របស់ ខ្លួន នោះឡើយ។ ហេតុនេះឯង បានជាពុទ្ធសាសនា មាន ទិដ្ឋិ ជា ធាតុ នៃ និច្ចលភាព នៅចំពោះ វិទ្យាស្ស្រ្ត ដែល អាច កែប្រែបាន តាម ការរកឃើញ នូវ ចំណេះថ្មី នៅ តែ មាន សីលធម៌ ខ្ពង់ខ្ពស់ ប្រកប ដោយ ឫទ្ធានុភាព ជានិច្ច សំរាប់ ការរស់នៅ។ ការយល់ឃើញ ថា ពុទ្ធសាសនា ឬ គ្រប់សាសនា ត្រូវ តែ កែប្រែ ខ្លះ ឲ ស្រប នឹង ការវិវត្តន៍ នៃ សង្គមមនុស្សលោក ជា ការយល់ឃើញ មាន ទំនាស់ មតិ រវាង អ្នក យល់ស្រប និង មិនយល់ស្រប។ ចំពោះ អ្នកយល់ស្រប មាន មតិ មួយ ថា ទ្រឹស្ដី សាសនា ជាទ្រឹស្ដី ដូច ជា ទ្រឹស្ដី នៃ សង្គម ឯទៀតៗ របស់ មនុស្សលោក ហើយ គ្រប់ ទ្រឹស្ដី នៃ សង្គម តែងតែ អះអាង ថា សំរាប់ បំរើ ប្រយោជន៍ មនុស្ស ដូច្នេះ បើ មាន ការវិវត្តន៍ នៃ សង្គម ហើយ ដើម្បី បំរើ ប្រយោជន៍ មនុស្សលោក វា ជា ការ ធម្មតា ទ្រឹស្ដី សាសនា ត្រូវ តែ មាន ការកែប្រែ នោះឯង។ ដូច បាន ជំរាប ខាងលើ រួចហើយ ថា មាន ជំនឿ លើ ធម្មជាតិ ដែល គេអាច ហៅបាន ថា ជា សាសនា ធម្មជាតិ (religion naturelle)។ សាសនា ធម្មជាតិ មាន មូលដ្ឋាន តែមួយគត់ គឺ អត្តភាព នៃអាទិទេព ដែល ជា អ្នក បង្កើត គ្រប់វត្ថុ ទាំងអស់ មាន ជីវិតក្ដី អត់ជីវិតក្ដី នៅក្នុងលោកា ក្នុង គោលបំណង តែ មួយគត់ គឺ បង្កើត «ការចេះដឹង» ដែល មាន ច្បាប់ អាទិទេព ជា ច្បាប់ ដឹកនាំ លោកា (univers) គឺថា ឆន្ទៈ របស់ អាទិទេព ជា អ្នកបង្កើត លោកា តែម្ដង ព្រោះ អាទិទេព ជា «សីលធម៌» ជាសុក្រិត ដូច្នេះ វាជា ការប្រមាថ ដល់ អាទិទេព បើ មនុស្សលោក ដែល អាទិទេព ជា អ្នកបង្កើត លើកយក អត្តភាព របស់ ព្រះអង្គ មក ពិចារណា។ បើ ជា សីលធម៌ ជា សុក្រិត ដូច្នេះ វា គ្មាន អ្វី ដែល ត្រូវ យកមក ធ្វើការកែ ទម្រង់ នូវ សីលធម៌ នេះឡើយ ព្រោះ វា គ្មាន អ្វី ជា អាក្រក់ អ្វី ជា ល្អ ព្រោះ វា រួមគ្នា តែ មួយ នៅក្នុង ច្បាប់អាទិទេព ដែល ជា អាទិទេព គ្មាន ដើមកំណើត គ្មាន អវសាន នៃ អត្តភាព។ ដូច្នេះ សេចក្ដីស្លាប់ របស់ មនុស្សលោក គ្រាន់ តែ ជា ការ ប្ដូរ រូប តែប៉ុណ្ណោះ ព្រោះអាត្ម័ន នៃ មនុស្សលោក គ្រាន់តែ ជា ចុណ្ណភាព (particule) មួយ នៃ អាទិទេព។ ឧទាហរណ៍ ដបមួយ អណ្ដែត នៅក្នុង មហាសាគរ បើ គេ វាយ បំបែក ដបនោះ វាបែក ជា ចំណែក ហើយ លិច ក្នុង មហាសាគរ កើត ជា ទ្រង់ទ្រាយ ថ្មី មួយ ទៀត តែប៉ុណ្ណោះ។ អ្នកកាន់ ពុទ្ធសាសនា ដឹងយល់ អំពី នត្ថិភាព (ភាពគ្មាន) នៃ បុគ្គល ព្រោះ ព្រះពុទ្ធ ធ្លាប់ពន្យល់ ច្បាស់លាស់ អំពី ភាពគ្មាន នេះឯង។

គ្រប់ សាសនា មាន សណ្ដាប់ធ្នាប់ ពីរយ៉ាង៖ ទី១ គឺ ទិដ្ឋិ (dogme) ដែល មាន ចែង ច្បាស់ អំពី គោល នៃ សីលធម៌ និង វិធី សំរាប់ ប្រតិបត្តិ ទី២ គឺ ទ្រឹស្ដីដើម ដែល មាន ការវិវត្តន៍ ទៅតាម ការវិវត្តន៍ នៃ សង្គម ជាពិសេស តាម ឥទ្ធិពល នៃ វិទ្យាស្ស្រ្ត ដែល សាសនា ទទួលស្គាល់ ថា ជា ចំណេះ សំរាប់ ការជឿនលឿន នៃ មនុស្សជាតិ តែ សាសនា មិនបោះបង់ទិដ្ឋិ របស់ ខ្លួន ជាដាច់ខាត ព្រោះ វាជា សារជាតិ នៃ អត្តភាព របស់ខ្លួន

តែម្តង។ ម្យ៉ាងមួយទៀត វិទ្យាសាស្ត្រ ទោះបី ខ្លួន មាន ការចំរើនលូតលាស់ រហ័សយ៉ាង ណា ក៏ដោយ ក៏ពុំទាន់ ពន្យល់បាន លើអ្វី ដែល ជា ភូមិ (domaine) នៃ ទិដ្ឋិសាសនា ឬ បរមវិជ្ជា នោះបានដែរ ដូច្នេះ បោះបង់អ្វី ដែល គ្មានអ្វី មកជំនួសបាន គឺ នាំអោយខាត ប្រយោជន៍ ដល់ មនុស្សលោក ព្រោះ សាសនា វា ជា ជម្រក នៃ សេចក្តីសុខ ក្នុង ផ្នែក ស្មារតី របស់ មនុស្សលោក។ គេអាចទុក សាសនា ជា ឧបរិរចនាសម្ពន្ធ[1] រីឯ វិទ្យាសាស្ត្រ វិញជា ហេដ្ឋារចនាសម្ព័ន្ធ[2] រស់រួមគ្នា ដើម្បី មនុស្សជាតិ។

មាន អ្នកប្រាជ្ញ បស្ចិមប្រទេស ខ្លះ យល់ ឃើញ ពុទ្ធសាសនា ជា សាសនា គ្មាន អាទិទេព តែ យោបល់នេះ មិនបាន ពិនិត្យ អោយបាន ជាក់លាក់ អំពី ប្រភពដើម នៃ ពុទ្ធសាសនា ជា ពិសេស អំពី ជាតិកំណើត និង ជីវិត របស់ ព្រះពុទ្ធ នោះឯង។ ត្រូវដឹង ថា ព្រះពុទ្ធ ព្រះអង្គ កើត នៅ ក្នុង គ្រួសារ អ្នកកាន់ ព្រហ្មញ្ញសាសនា ក្នុង វណ្ណៈ ក្សត្រិយៈ ហើយ ទទួល ការអប់រំ ជ្រៅជ្រះ ពី ព្រាហ្មណ៍ ដូច្នេះ មូលដ្ឋាន នៃ ការរាវរក ផ្លូវថ្មី របស់ ព្រះអង្គ គឺ លទ្ធិព្រហ្មញ្ញសាសនា នោះឯង អាស្រ័យហេតុនេះ បាន ជា គេ ឃើញ ថា មូលដ្ឋានលទ្ធិ ព្រហ្មញ្ញសាសនា នឹង ពុទ្ធសាសនា មាន គោលការណ៍ ដូចគ្នា ច្រើនណាស់។ ចំណុច ដែល ខុសគ្នា គឺ នៅក្នុង ពុទ្ធសាសនា ទទួល យក មនុស្ស គ្រប់ វណ្ណៈ ដែល មាន បំណង ធ្វើ បរិវត្ត (ផ្លាស់សាសនា) មក ប្រតិបត្តិ ធម៌ព្រះពុទ្ធ វិញ។ ព្រះពុទ្ធ ព្រះអង្គ មិន ដែល រិះគន់ ព្រហ្មញ្ញសាសនា និង ធ្វើ បដិវត្តន៍ វណ្ណៈ ដូច មាន អ្នកខ្លះ យល់ ច្រឡំ ថា លទ្ធិពុទ្ធសាសនា និង កុម្មុយនិស្ត មាន ធាតុ ដូចគ្នា ព្រោះ មាន ការតស៊ូ វណ្ណៈ ដូចគ្នា។ រីឯ ការគោរព អាទិទេព ទាំងពួង នៃ ព្រហ្មញ្ញសាសនា ព្រះអង្គ មិន ដែល លើក យក មក បញ្ជាក់ ថា ព្រះអង្គ នៅជឿ ឬ មិនជឿ នោះទេ ព្រោះ ព្រះអង្គ យល់ឃើញ ថា ក្នុង ជំនឿនេះ វា មាន រួចស្រេច ទៅ ហើយ នៅ ក្នុង អារម្មណ៍ របស់ ព្រះអង្គ និង ប្រជាជន ដែល មាន បំណង យក ធម៌ព្រះអង្គ ជា ផ្លូវថ្មី សំរាប់ រំដោះ ទុក្ខ នៃ មនុស្សលោក។ ដូច្នេះ លើក យក ចំណុច នេះ មក បងស្រាយ វា គ្មាន ប្រយោជន៍ អ្វី បន្ថែម នោះឡើយ តែ ជំនឿ របស់ ព្រះពុទ្ធ លើ អាទិទេព ខុសត្រង់ ព្រះអង្គ អប់រំ មនុស្សលោក អោយ ពឹង ផ្អែក លើ ខ្លួនឯង ដើម្បី រំដោះខ្លួន អោយ ចាកផុត អំពី វដ្តសង្សារ (កើតស្លាប់ ស្លាប់កើត) ដែល ជា ប្រភព នៃ ទុក្ខ របស់ មនុស្សលោក នោះឯង។ ការណ៍នេះ ដែល នាំអោយ អ្នកខ្លះ យល់ ច្រឡំ ថា ពុទ្ធសាសនា ជា សាសនា គ្មាន អាទិទេព នោះ ឯង ឬ មិនមែន ជា សាសនា តែ គ្រាន់ តែ ជា ឳវាទ របស់ ព្រះពុទ្ធ ដែល ជា មនុស្ស ពិសិដ្ឋ តែប៉ុណ្ណោះ។

[1] Superstructure។
[2] Infrastructure។

## ពុទ្ធសាសនានៅស្រុកខ្មែរ

ខ្មែរធ្លាប់ ជា ប្រទេស ថ្កុំថ្កើង រហូតដល់ចុងសតវត្សទី១៣ នៅក្នុងដំបន់អាស៊ីប៉ែក អគ្នេយ៍។ ទោះបី នៅរយៈពេលនោះ ជា ប្រទេស មាន ព្រហ្មញ្ញសាសនា ជា ជំនឿសាសនា របស់ វណ្ណៈ អ្នកដឹកនាំ តែ វណ្ណៈ នេះ មាន ការអនុគ្រោះច្រើន ដល់ពុទ្ធសាសនា ដែល ជា ជំនឿ របស់ ប្រជារាស្ត្រខ្មែរ។ ត្រូវដឹងថា ព្រះពុទ្ធ ត្រូវ ពួកព្រាហ្មណ៍ ទុក ព្រះអង្គ ជា អវតា នៃ ព្រះវិស្ណុ ក្នុង ចំណោម អវតា ចំនួន ១០ ដង គឺៈ មត្ស្យ, កុម៌, វារាហ, នរសិង្ហ, វាមន, បរសុរាម, រាម, ក្រឹស្ណ, ពុទ្ធ និង កល្កិន។

នៅក្នុង សតវត្ស ទី១៤ ប្រទេសខ្មែរ ចាប់ផ្ដើម ស្គាល់ នូវ ឱនភាព មាន ហេតុផល ពី កំហុស ជាច្រើន របស់ អ្នកដឹកនាំ ដែលនាំ ឲអ្នកខ្លះ លើក បញ្ហា ព្រហ្មញ្ញសាសនា មក ធ្វើ ជា អាថ៌ហេតុ នៃ ឱនភាព តែម្ដង ដែលនាំឲ មាន កើតហេតុ ចលាចល មួយ នៅ ក្នុង មហានគរ គឺមាន ជម្លោះ រវាង អ្នកកាន់ ព្រហ្មញ្ញសាសនា នឹង អ្នកកាន់ពុទ្ធសាសនា នៅក្នុង មជ្ឈដ្ឋាន អ្នកដឹកនាំ ដែល គេ អាច ចាត់ទុក ថា ជា ដើមហេតុ មួយ នៃការរលំ វប្បធម៌អង្គរ។ ហេតុ នេះ ឯង បាន ជា មាន អ្នកចេះដឹង ខ្មែរ ខ្លះ ដែល មាន ទំនោរចិត្ត ទុក ពុទ្ធសាសនា ជា សាសនា បញ្ញើក្អែក នៅក្នុង សង្គមខ្មែរ មាន វិស័យមតិ ថា ព្រះពុទ្ធសាសនា ជា គោលហេតុ នៃ ឱនភាពខ្មែរ ព្រោះតាំងពី ពុទ្ធសាសនា ក្លាយ ជា សាសនាជាតិ ស្រុកខ្មែរ ក៍ ចាំផ្ដើម ចុះទន់ខ្សោយ។ ជម្លោះ សាសនា នេះ នៅក្នុង មជ្ឈដ្ឋាន អ្នកដឹកនាំខ្មែរ នៅ សតវត្ស ទី១៤ បានបញ្ចប់ ជាស្ថាពរ ដោយ ក្រុមអ្នកកាន់ ពុទ្ធសាសនា មាន ជ័យជំនះ ហើយ នាំគ្នា លើក តា ត្រសក់ផ្អែម ឡើង សោយរាជសម្បត្តិ គ្រប់គ្រង ក្រុង កម្ពុជាធិបតី នៅក្នុងឆ្នាំ ១៣៤០។ ជ័យជំនះ នេះ បាន មកពី រដ្ឋប្រហារ មួយ ដឹកនាំ ដោយ ពួកមន្ត្រី ជាន់ខ្ពស់ មួយក្រុម ដែល មាន តា ត្រសក់ផ្អែម ចូលរួម ជា សកម្ម ហើយ ជា អ្នកសម្លាប់ស្ដេច តែម្ដង។ ព្រឹត្តិការណ៍ នេះ មិននាំ បង្កើត សង្គ្រាម ស៊ីវិល រវាង គូរ បដិបក្ខ នោះឡើយ ព្រោះ ក្រោយ ពី បាន ជ័យជនះ ក្រុម ព្រះបាទ ត្រសក់ផ្អែម នៅ តែ រក្សា ប្រពៃណីយ នៃ ពិធីមង្គលរាជកិច្ច នៃ ព្រះមហាក្សត្រ ដែល មាន ពួក ព្រាហ្មបុរោហិត ជា ពិធីករ នៅក្នុង ព្រះរាជវាំង ជា និច្ច។ វិធានការ បែបនេះ គឺ ធ្វើឡើង នៅ ក្នុង គំនិត រក សមតា រវាង ពុទ្ធសាសនា នឹង ព្រហ្មញ្ញសាសនា នៅក្នុង វណ្ណៈ អ្នកដឹកនាំ គឺថា នៅ តែ ទុក ព្រហ្មញ្ញសាសនា ជា មរតក នៃ វប្បធម៌ របស់ រាជវង្សានុវង្សខ្មែរ តែ ប្រកាន់ យក ពុទ្ធសាសនា ជា សាសនា របស់ ជាតិខ្មែរ ដែល ជា សាសនា របស់ ប្រជារាស្ត្រ ព្រោះគេ លែងទុក មហាក្សត្រ ជា អាទិទេព តែ ជា អច្ឆរិយបុគ្គល ទទួល គុណស្រ័យ (កុសល

កម្ម) ពី អតិតជាតិ កើត ជា អ្នកមានបុណ្យ ក្នុង បច្ចុប្បន្នជាតិ សំរាប់ ដឹកនាំ នគរ ប្រកប ទៅដោយ ទសពិធរាជធម៌។

យើង ដឹង ថា ព្រហ្មញ្ញហ៍ក្តី នឹង ពុទ្ធសាសនាក្តី បាន ជ្រួលជ្រាប នៅ ក្នុង របប ជីវិត នៃ ប្រជាជនខ្មែរ ហើយក្លាយទំនៀមជាតិ ហើយ ពុទ្ធសាសនា ក៏បានក្លាយ ជា គ្រិះ នៃ ជាតិខ្មែរ ចាប់ពី សតវត្សទី ១៤ មក។ ប្រជាជនខ្មែរ ទាំងប្រុស ស្រី ភាគច្រើន ទុកខ្លួន ជា ឧបាសក ឧបាសិកា អ្នកកាន់ពុទ្ធសាសនា ធ្វើ បុណ្យឲទានរក្សាសីល៥ សីល ៨ សីល ១០ ជា ដើម ហេតុនេះឯង បាន ជា ពុទ្ធសាសនា ចូល ស៊ុបសូន ចាក់ឫស យ៉ាង មាំ ក្នុង សង្គមខ្មែរ ទំនោរខ្មែរ មនោគមខ្មែរ ដែល មាន ជា អាទិ ក្នុង៖ ជំនឿប្រពៃណី ទំនៀមទម្លាប់ សិល្បះ និង អក្សរសិល្ប៍។ ជំនឿខ្មែរ មាន ជា អាទិ៖ ជំនឿបុណ្យបាប កម ផល សច្ចះ សុចរិត យុត្តិធម៌ ស្ថានសួគ៌ ស្ថាននរក ។ល។ (*សូមអាន សៀវភៅរបស់ លោក ទាវ ឆៃសុក មាន ចំណងជើង ថា «វប្បធម៌-អរិយធម៌ ខ្មែរ-ឥណ្ឌា*)។ ជំនឿទាំង នេះ ហើយ ដែល ជា កត្តា ដ៏ ធំ មួយ សំរាប់ ជីវភាពរាល់ថ្ងៃ នៃ ប្រជាជនខ្មែរ ជួនកាល ក៏ ទុក ជា អន្តរការណ៍ (inconvénient) សំរាប់ ការរស់នៅ ក្នុង សង្គមសម័យ ជួនកាល ក៏ ទុក ជា ជំនួយ ចិត្ត សំរាប់ ការស់នៅ ក្នុង សង្គម ទុក សម្ភារះ ជា តម្លៃ នៃគោល ជីវិត ដែល នាំ ឲ សង្គម ខ្វះ សីលធម៌ មនុស្សធម៌ ដែល ជា ស្នូលដើម នៃ មនុស្សជាតិ។ ការណ៍នេះ ដែល នាំឲ មាន ការពិភាក្សាសា នៅក្នុង សង្គម ស្តីអំពី តួនាទី នៃពុទ្ធសាសនា ក្នុង ឪនភាព នៅ ស្រុកខ្មែរ ដែល ពួក ខ្មែរ កុម្មុយនិស្ត និង អ្នកឆ្វេងនិយម ទុក ជា ប្រធានបទ សំខាន់មួយ ដើម្បី ជា ទម្រ នៃ ការតស៊ូ វណ្ណៈ ដោយ ទុក ពុទ្ធសាសនា ជា ដំបៅមួយ ក្នុងចំណោម ដំបៅ ដទៃទៀត នៅ ក្នុង សង្គមខ្មែរ។

---

## ទស្សនៈវិជ្ជា

---

ពុទ្ធសាសនា ក៏ដូច សាសនា ដទៃទៀត មានចែក ជា ពីរ ផ្នែក៖ ផ្នែកសំខាន់ ដែល ជា ផ្នែក ទស្សនៈវិជ្ជាសាសនា និង ផ្នែក បន្ទាប់បន្សំ ដែល ជា ផ្នែកសីលធម៌។ តែនៅ ក្នុងការវិវត្ត នៃ សាសនា គេឃើញថា ផ្នែក សីលធម៌ ក៏ បាន រលាយ ចូលទៅ ក្នុង ផ្នែក ទស្សនៈវិជ្ជាសាសនា រហូតក្លាយ ជា ទិដ្ឋិ តែមួយ ដែលនាំ ឲអ្នកមានជំនឿ លើ សាសនា ទុក សីលធម៌ ជា ធម៌ សាសនា តែម្តង។ អាស្រ័យហេតុនេះ បាន ជា សាសនា ដែល មាន ទិដ្ឋិ និច្ចល អាច ទុក ធម៌ របស់ខ្លួន ជា សីលធម៌ ខ្ពង់ខ្ពស់ សំរាប់ ជីវភាពរាល់ថ្ងៃ របស់ មនុស្ស។ ការណ៍នេះ ដែល នាំឲ មាន ទំនាស់ រវាង សាសនា និង វិទ្យាសាស្ត្រ ព្រោះ





ថា ជួនកាល សាសនា យក វិធី សីលធម៌ ខ្លះ ទុកជា ជំនឿពិសិដ្ឋ របស់ខ្លួន ដែល វាផ្ទុយ ស្រឡះ ពី ចំណេះ វិទ្យាសាស្ត្រ ដែល ជា ពន្លឺ នៃ បញ្ញា នៃ មនុស្សលោក។ ទំនាស់នេះ ក៏ មាន ជាមួយនឹង ទស្សនៈវិជ្ជា នោះដែរ ព្រោះ ទស្សនៈវិជ្ជា មាន អំពល់ ខ្លាំង អំពី ការ ចាប់ បដិសន្ធិ នៃ ធម្មជាតិ សារជាតិ នៃ ដើមហេតុ ក្នុង រូបភាព អរូបិកម្ម (abstraction) និង ច្បាប់ ព្រោះ សាសនា តែងតែទុកខ្លួន ជា អ្នក មាន លទ្ធភាព ឯការធិភាព អាច ពន្យល់បកស្រាយ នូវ បាតុភូត នៃ ធម្មជាតិ។ តែ ការពន្យល់បកស្រាយ របស់ សាសនា វាខុសពី ទស្សនៈវិជ្ជា ព្រោះ សាសនា ទុក ធម្មជាតិ ជា ស្នាដៃ របស់ អាទិទេព ហើយ យក លោកកថា (légende) របស់ អ្នកដែលបានថ្លែងវា ក្នុងនាម នៃ អាទិទេព មក ធ្វើ ជា ជំនឿ ហើយ ទុក វា ជា ប្រវត្តិសាស្ត្រ នៃ សាសនា តែ ម្តង ដូច យ៉ាង សៀវភៅ Bible សំរាប់ គ្រិស្តសាសនា រឿងជាតិ របស់ ព្រះពុទ្ធ សំរាប់ ពុទ្ធសាសនា វេដា សំរាប់ ព្រហ្មញ្ញសាសនា ។ល។ ឧទាហរណ៍៖ រឿង មានចែង នៅក្នុង សៀវភៅ Bible ពួកអ្នក កាន់សាសនាគ្រិស្ត ត្រូវតែជឿវា ជា ដាច់ខាត ព្រោះ រឿងហ្នឹង ត្រូវ ពួកសហធម្មិក គេ យកវា មក ធ្វើ សាសនាវូបនិយកម្ម ក្លាយ ជា ទិដ្ឋិ។ ម្យ៉ាងមួយទៀត នៅចំពោះមុខ ឬទ្ធានុភាព នៃ សហធម្មិក អ្នកមានជំនឿ លើ សាសនាគ្រិស្ត គ្មានជម្រើស ថានឹងជឿ រឿង មាន កត់ត្រាទុក នៅក្នុង សៀវភៅ Bible នោះបានឡើយ។ ការណ៍នេះ ក៏មាន នៅក្នុង ព្រហ្មណ៍សាសនា នោះដែរ។ ចំពោះ ពុទ្ធសាសនា មាន លក្ខណ: ពិសេសមួយ គួរ តែកត់សំគាល់ គឺ គេឃើញ គ្មាន ការបង្ខំ ពីសំណាក់ សហធម្មិក ឲជឿដាច់ខាត លើ នោះឡើយ តែដោយសារ ឧបាសក ឧបាសិកា ភាគច្រើន មាន ជំនឿ ងប់ងល់ ក៏ មិន ហ៊ាន យកវា មក ពិចារណា រក ហេតុផល ដើម្បី ពន្លិច រាវរក ការពិត នោះដែរ។ មាន អ្នកប្រាជ្ញ ខ្លះ ធ្វើសង្ខេប ថា ទី១ គឺ ជឿងប់ ព្រោះ ខ្លាច ទី២ គឺ ជឿងប់ ព្រោះ ល្ងង់។ សភាព ខ្លាច និង ល្ងង់ នេះឯង ដែល ទស្សនៈវិជ្ជា បោះបង់ គំនិតនេះចោល ហើយ យក ការពិចារណា រាវរក ការពិត អំពី ធម្មជាតិ ដោយ គ្មានជំនឿ ដាច់ខាត ថា ធម្មជាតិ បង្កើតឡើង ដោយ អាទិទេព។ តែ សាសនា និង ទស្សនវិជ្ជា មាន គោលការណ៍ រួមមួយ ដូចគ្នា គឺ នាំ មនុស្សលោក អោយ ចាកផុត ពី ជំនឿលើ ធម្មជាតិ ៖ ចំពោះសាសនា គឺ អោយជឿ លើ ខ្លួន ព្រោះ ខ្លួន មាន ទ្រឹស្តី ពិតប្រាកដ សំរាប់ ជា ទម្រ នៃ ជំនឿ រីឯ ទស្សនៈវិជ្ជា វិញ យក ការពិចារណា ដែល នាំ មនុស្សលោក រក ការពិត ដោយខ្លួនឯង អំពី បដិសន្ធិ នៃ ធម្មជាតិ សារជាតិ នៃ ដើមហេតុ ក្នុង រូបភាព អរូបិកម្ម។ នៅបស្ចិមប្រទេស ក្នុង កាលសម័យ នៃ ពន្លឺបញ្ញា (époque des Lumières) ទំនាស់ រវាង សាសនា និង ទស្សនវិជ្ជា មាន លក្ខណ: ជា ទំនាស់ ស្មារតី តែប៉ុណ្ណោះ ក្រោយពី សាសនា ក្នុង ជំនឿដើម របស់ខ្លួន ចាប់ផ្តើម ចុះអន់ថយ នៅចំពោះមុខ វិទ្យាសាស្ត្រ ដែល ត្រូវ ពួក ទស្សនវិទូ ជាច្រើន យកវា មកធ្វើ ជា ទម្រ នៃ ការពិចារណា របស់ខ្លួន ជា ពិសេស នៅក្នុង កាលសម័យ នៃពន្លឺបញ្ញា ត្រូវ បាន មហា

ក្សត្រ ច្រើន អង្គ នៅ ទ្វីបអ៊ឺរ៉ុប មាន ចិត្ត ចង់ ចេះដឹង អំពីទស្សនវិជ្ជា ព្រោះ យល់ឃើញ ថា វា អាចមាន ប្រយោជន៍ ដល់ នយោបាយ ដឹកនាំ របស់ខ្លួន។ ការណ៍នេះ ដែលនាំ ឲ មាន ការបែកចែក នូវ សីលធម៌ ពីរ យ៉ាង មួយ ជា សីលធម៌-សាសនា មួយទៀត ជា សីលធម៌-មនុស្សធម៌ (éthique séculière)។ នា បច្ចុប្បន្ននេះ ព្រះអង្គ Dalaï-Lama យល់ឃើញ ថា សីលធម៌-មនុស្សធម៌ នេះ មាន សារៈសំខាន់ ជាង សាសនា ទៅទៀត សំរាប់ ការរស់នៅ របស់ មនុស្សលោក នៅក្នុង ពិភពលោក នា វិភាគកាល (à l'aube) នៃ សតវត្ស ទី២១ នេះ។

ជាយូរយារ ណាស់មកហើយ គេតែងទុក ទស្សនវិជ្ជា នៃ ប្រទេស ក្រិច ជា ការសិក្សា អំពី ធម្មជាតិ ដែល លោក សូក្រាដ តែងតែ ទុក មនុស្សលោក ជា ស្នូល។ ទស្សនៈនេះ ដែល នាំ ឲ គេ ទុក លោក សូក្រាដ ជា «មនុស្សដើម នៃ សតិសម្បជញ្ញៈ» (primat de la conscience) ឬ ជា អ្នកអះអាង អំពី ប្រធានបទ នៃ ការសិក្សា នេះ។ តែ តាម ពិត លោក សូក្រាដ គ្រាន់តែ បន្ត ការពិចារណា លើ ធម្មជាតិ ពី ទស្សនវិទូ ផ្សេងៗ ឯទៀត មុន គាត់ តែ ប៉ុណ្ណោះ ដូចគាត់ ធ្លាប់ឆ្លើយនឹង សំនួរ តុលាការ កាត់ទោសគាត់ថា « លោកចោទប្រកាន់ខ្ញុំ ថា ខ្ញុំ ជា អ្នកនិយាយថា ព្រះអាទិត្យ គ្រាន់តែ ដុំថ្មមួយដុំ ដែល កំពុងឆេះ និង ព្រះចន្ទ ជា ផែនដី មួយទៀត។ សំដី របស់ ខ្ញុំនេះ គ្រាន់ តែ ខ្ញុំលើកយក មក និយាយ ដែល មាន គេ ធ្លាប់ និយាយ រួចហើយ នៅ ក្នុង សតវត្ស ទី៤ (ស.ត.ទី៤ មុន គ.ស.) តែ ប៉ុណ្ណោះ។ បើ យោង តាម សំដី របស់ លោក សូក្រាដ គេ អាច សន្និដ្ឋាន បានថា គោល នៃ ការសិក្សា នៃ ទស្សនវិជ្ជា នៅពេលនោះ (ស.ត.ទី៥ មុន គ.ស.) គឺ ឋិតនៅលើ ការលុបចោល នូវ អធម្មជាតិ (surnaturel) ក្នុង ការពន្យល់ លើ បាតុភូត នៃ ធម្មជាតិ ជាង ការ បង្ហាញ នូវ ពុទ្ធិ របស់ ខ្លួនឯង (connaissance de soi) ព្រោះ ថា នៅពេលនោះ រូបសាស្ត្រវិទ្យា លោកធាតុវិទ្យា និង ធម្មជាតិវិទ្យា សុទ្ធ តែនៅ ក្នុង ភូមិ នៃ ការសិក្សា របស់ ទស្សនវិជ្ជា ទាំងអស់។ មួយ ផ្នែកទៀត គេឃើញមាន ការ សិក្សា អំពី សីលធម៌ ច្រើនណាស់ដែរ តែ ច្រើន សំរាប់ យក មក ពិភាក្សា ក្នុង ភូមិ នយោបាយ ជាង ជា សីលធម៌ បរិសុទ្ធ ជា វិន័យ សំរាប់ យកមកប្រតិបត្តិ។ ការណ៍នេះ ជា ដំណើរ ដើរ ទៅរក វិទ្យាសាស្ត្រ ដែល នាំ ឲ មាន ទំនាស់ ជាមួយ ទិដ្ឋិ សាសនា ដូច ជា លោក សូក្រាដ ត្រូវ តុលាការ កាត់ទោស ប្រហារជីវិត ព្រោះ លោក បាន ផ្សាយ គំនិត ផ្ទុយនឹង ជំនឿ សាសនា ជា ឧទាហរណ៍។ យ៉ាងណាមិញ ទស្សនវិជ្ជា និង សាសនា រួមរស់ ជាមួយគ្នា ក្នុងជម្លោះ តែ ក្នុង គោលដៅ តែមួយ ដូច បាន ជំរាប ខាងលើរួច មកហើយ គឺ ទាញ មនុស្សលោក កុំអោយ ផ្អែក វាសនា របស់ខ្លួន ទៅលើ ច្បាប់ ធម្មជាតិ ទាំងស្រុង។ សាសនា យក ធម៌សាសនា ជា មូលដ្ឋាន សំរាប់ ពន្យល់ អំពី បាតុភូត នៃ ធម្មជាតិ រីឯ ទស្សនវិជ្ជា យក ការពិចារណា សំរាប់ រ៉ាវរក ការពិត នៃ បាតុភូត នៃ ធម្មជាតិ។

## ទស្សនវិជ្ជានៅស្រុកខ្មែរ

អ្នកចេះខ្មែរយើង មួយចំនួន តែងតែ អះអាង ថា ខ្មែរយើង គ្មាន ទស្សនវិជ្ជា នោះទេ ហើយ មាន អ្នកខ្លះទៀត យល់ឃើញ ថា អវត្តមាននេះឯង ដែល នាំ ឲ សង្គមខ្មែរ ជួបប្រទះនឹងឱនភាព ព្រោះ នៅក្នុង សង្គមខ្មែរ គ្មាន ការពិចារណា រក ហេតុផល អំពី ជំនឿ លើ សាសនា ប្រពៃណីជាតិ និង បាតុភូត នៃ ធម្មជាតិ។ កង្វះ នេះឯក ដែល ធ្វើអោយ សង្គម លែងប្រែប្រួល ទម្រង់ ទាំង ផ្នែក រូបបី និង មនោ (esprit) របស់ ខ្លួន។ តើ ការយល់ឃើញ បែបនេះ មាន ការពិត ដែរ ឬទេ ? បើ អ្នក ទាំង នោះ យល់ ឃើញ ថា ទស្សនះវិជ្ជា ជា យថាប្រភេទ (spécifiquement) នៃ មស្ចឹមប្រទេស ហើយ បើចង់ អះអាង ថា សង្គម ដែល នៅក្រៅ ពី មស្ចឹមប្រទេស មាន ទស្សនវិជ្ជា លុះត្រាតែ ទស្សវិជ្ជានោះ មាន លក្ខណៈ ដូចគ្នា បេះបិទនឹង ទស្សនវិជ្ជា នៃ មច្ចឹមប្រទេស។ បើយល់ឃើញបែបនេះ គឺ ពិត ជា ពុំអាច មើលឃើញ ថា នៅក្នុង សង្គមខ្មែរ អាចមាន ទស្សនវិជ្ជា នោះឡើយ។ តែបើ គេ យល់ឃើញ ថា ទស្សនវិជ្ជា ជា វិស័យ មួយ ដែល យក ការពិចារណា លើ គ្រប់ រូបភាព នៃ ជីវិត មាន នៅក្នុងលោកនេះ ជា មូលដ្ឋាន នៃ ពុទ្ធិរបស់ខ្លួន គេ អាច មើលឃើញ ថា នៅ ក្នុង សង្គមខ្មែរ ក៏មាន ទស្សនវិជ្ជា ដែរ គ្រាន់តែ របៀប នៃ ការពិចារណា មាន ភាពខុសគ្នា តែប៉ុណ្ណោះ។

គេអាច សួរទៅវិញ ថា តើ ទស្សនវិជ្ជា នៃ មស្ចឹមប្រទេស វា អាច ស្របនឹង មនោ នៃ សង្គមខ្មែរ ដែរឬទេ ? សំនួរ នេះឯងហើយ ដែលនាំឲយើងឆ្លើយតបវិញ ថា ការគ្មាន ទស្សនវិជ្ជា បែប បស្ចឹមប្រទេស នៅក្នុង សង្គមខ្មែរ មិនមែន ជា មូលហេតុ នៃ កង្វះ ការពិចារណា អំពី ធម្មជាតិ ដូចការអះអាង ខាងលើនេះឡើយ។ សង្គមខ្មែរ មាន ក្បួនច្បាប់សង្គម ច្រើនណាស់ សំរាប់ ជា វិធី សំរាប់ រស់នៅ ហើយ នៅក្នុងច្បាប់ទាំងឡាយ នោះទៀត គ្មានលក្ខណៈ ជាក្បួនបិទទ្វារ មិនឲយកវា មកពិចារណា រកហេតុផល ដូច ទិដ្ឋិ នៃ សាសនា នោះទេ។ ម្យ៉ាងមួយទៀត នៅក្នុង សេក្ខាបទ នៃ ធម៌ព្រះពុទ្ធ ដែល ក្លាយទៅជា វិធី សំរាប់ការរស់នៅ របស់ ខ្មែរ មាន ការបកស្រាយ អំពី ធាតុធម្មជាតិ និង សត្វលោក ដ៏ បរិបូរណ៍ សំរាប់ យកមក ពិចារណា។ យើង លើក យកឧទាហរណ៍ មួយ ក្នុងចំណោម ឧទាហរណ៍ ជា ច្រើន មក បង្ហាញ នូវ ការពិចារណា មាននៅក្នុង សិក្ខាបទ នៃ ធម៌ព្រះពុទ្ធ អំពី «នត្ថិភាព នៃ បុគ្គល[3]»៖ បុគ្គល មាន ឈ្មោះ សំរាប់ សំគាល់ ឬ សំរាប់ ហៅ តែ ឈ្មោះនេះ គ្រាន់ ជា សញ្ញាណ ធម្មតា ជា វិញ្ញាតិ (ការ

[3] Inexistence de l’individu។

សំដែងគំនិត) ធម្មតា តែ នៅ ក្នុង ឈ្មោះនេះ គ្មាន បុគ្គល នោះឡើយ។ ដូចយាំង សក់ក្តី រោមក្តី ក្រចកក្តី ធ្មេញក្តី សាច់ខ្លួនក្តី ឆ្អឹងក្តី សតិសម្បជញ្ញៈក្តី វេទនារម្មណ៍ក្តី ការយល់ដោយវិញ្ញាណក្តី ។ល។ របស់ បុគ្គលនោះ តើ អាច បញ្ជាក់ អំពី អត្ថភាព នៃ បុគ្គលនោះបានដែរ ឬទេ ? ឧបមា រទេះ ផ្គុំ ដោយ ភ្លៅរទេះ (essieu) កង់ នឹម បង្ហៀ (rêne) ទម្រងបុស្បក (support du dais) ជន្លួញ (aiguillon) និង ហិបរទេះ ហើយ វត្ថុធាតុនិមួយៗនេះ ឬ ការផ្គុំគ្នា អាច សំគាល់ ថា ជា រទេះបាន ដែរ ឬទេ ? ទម្រង (forme) នេះ មិនមែន ជា រទេះ នោះឡើយ ព្រោះ រទេះ គ្រាន់ តែ ជា ពាក្យសន្មត់ មួយមាត់ តែប៉ុណ្ណោះ ទោះបី ទម្រង នេះមាន ឈ្មោះ សំរាប់ហៅ មាន សញ្ញាណ ទូទៅ មាន វិញ្ញាតិ ធម្មតា ក៏ដោយ តែ ការពិត អ្វី ដែល មាន ដូចបាន រៀបរាប់ ខាងលើ នេះ វា មិនមែន ជា បុគ្គល និង ជា រទេះ នោះឡើយ។ យើង ដឹងដែរ ថា ការពិចារណា អំពី នត្ថិភាព នៃ បុគ្គល នេះ ក៏ មាន នៅក្នុង ទស្សនវិជ្ជា បស្ចឹមប្រទេស ជា ពិសេស នៅ លើ សារជាតិ នៃ «ភាវៈ» និង «អភាវៈ» (non-être)។ ចំពោះ ខ្មែរ ពាក្យ ទស្សនវិជ្ជា ជា ពាក្យ អភិនព (ថ្មីណាស់) សំរាប់ ប្រើ ក្នុង មុខវិជ្ជា Philosophie ដែល ជា វិជ្ជា របស់ មស្ចឹមប្រទេស ដែល ខ្មែរយើង យកមក បញ្ចូល ក្នុង កម្មវិធីសិក្សា តែ មិនមាន ន័យ ថា ខ្មែរ គ្មាន ពាក្យ ពី បុរាណកាល មាន ន័យ ប្រហាក់ប្រហែលនឹង ពាក្យ ទស្សនវិជ្ជា នោះដែរ។ ដូច ជា ពាក្យ គតិលោក ដែល វិញ្ញូ បុរាណខ្មែរ ប្រើ សំរាប់ ធ្វើអត្ថាធិប្បាយ អំពី ចិត្តនាការ (pensée) ស្តីពី ធម្មជាតិ និង ជីវិតសត្វលោក នៅក្នុងលោក តែ លក្ខណៈ ចិត្តនាការ នៃ ទស្សនៈវិជ្ជា មាន របៀប បែប ជា វិជ្ជា រីឯ គតិលោក វិញ ជា សីលធម៌ តែ ចិត្តនាការ ទាំង ពីរ នេះ មាន ប្រភព ដូចគ្នា គឺជា ចិត្តនាការ នៃ មនុស្ស សំរាប់ ការរស់នៅ ដោយ សុខសាន្ត។ វិជ្ជា ជា ពុទ្ធិ ចំហ សំរាប់ យក មក ពិចារណា ឬ ប្រតិបត្តិ តាម តែ មិន បិទទ្វារ ដល់ ការស្វែងរក នូវ ការចំរើនលូតលាស់ ព្រោះ សង្គមមនុស្ស ជា សង្ឃតភាវៈ (Etre vivant) ដ្បិទ មនុស្សលោក ជា សត្វលោក មានបញ្ញា ដែល ជា ធម្មជាតិ របស់ ខ្លួន។ ចំណែក សីលធម៌ ជា ក្បួនបិទទ្វារ សំរាប់ អនុវត្តន៍ ដើម្បី រស់នៅ ក្នុង ករុណ (bonté) និង សមធម៌ (équité) ដែលជា មូលដ្ឋានសីល នៃ សុខដុមសង្គមមនុស្ស។ តែ សីលធម៌ ខុសពី ទិដ្ឋិ នៃ សាសនា ព្រោះ វា គ្រាន់តែ ជា ឱវាទ គ្មាន ការបង្ខំ ដាច់ខាត ឲ អនុវត្តន៍តាម នោះឡើយ។ នៅក្នុងចំណុច នេះឯង ព្រះពុទ្ធសាសនា មាន ទ្វេតួនាទីៈ ទី១ ជា សាសនា ព្រោះ មាន ពិធី សាសនា ច្បាស់លាស់ សំរាប់ អនុវត្តន៍ ដើម្បី ស្វែងរក បរមសុខ ទី២ ជា ទស្សនៈវិជ្ជា ព្រោះ ធម៌ព្រះពុទ្ធ ជា វិជ្ជាគតិមួយ សំរាប់ មនុស្សលោក យកមក ពិចារណា ដោយខ្លួនឯង រិះរក ផ្លូវ សំរាប់រក លោកិយសុខ ដែល ជា ជវនចិត្តទៅរកសុភមង្គល (Aspiration au bonheur) និង សុខុមាលភាព។ យ៉ាងហ្នឹងហើយ បាន ជា យើងឃើញ នៅក្នុង សង្គមខ្មែរ មាន ច្បាប់មនុស្សធម៌ ជា ច្រើន ដែល ជា និស្សន្ទវត្ថុ (dérivée) ចេញអំពី ធម៌ព្រះពុទ្ធ តែគ្មាន សារ

ជាតិ ជា ធម៌សាសនា នោះឡើយ ព្រោះ អ្នកតែងច្បាប់ ទាំងនោះ សុទ្ធ ជា គន្ថរចនាចារ្យ (écrivain moraliste) ឬ ជា មនុស្សនិយម យក ធម៌ព្រះពុទ្ធ មកច្នៃ ជា សីលធម៌-មនុស្សធម៌ សំរាប់ ជីវភាពរាល់ថ្ងៃ នៃ មនុស្សលោក នៅក្នុង «អភិញ្ញា ៥ » នៃ ពុទ្ធសាសនា។ ហេតុនេះឯង បាន ជា ធម៌ព្រះពុទ្ធ ផ្ចិតជាប់ នៅក្នុង របបជីវិត របស់ជនខ្មែរ ម្នាក់ៗ ក្លាយ ជា ទំនៀមជាតិខ្មែរ។

សង្គមខ្មែរ គ្មាន ទស្សនះវិជ្ជា បែប បស្ចឹមប្រទេស ពិតមែន តែ មាន សីលធម៌-មនុស្សធម៌ (éthique séculière) គ្រប់គ្រាន់ ជា មូលដ្ឋាន សំរាប់ ពិចារណា អំពី បរមត្ថវិជ្ជា ផង និង សីល (conduite éthique) នៃ មនុស្សលោក ផង។ តែខ្មែរយើង ដឹងថា ស្រុកខ្មែរ តាំងពី សតវត្សទី១៤ មក បានជួបប្រទះនឹង វិបត្តិ នយោបាយ ទាំងក្នុង និង ក្រៅប្រទេស សង្គមកិច្ច សេដ្ឋកិច្ច និង សីលធម៌ ដែល ជា កត្តា ទាញ ស្រុកខ្មែរ ឲធ្លាក់ ក្នុង ឪនភាព។ ការណ៍នេះ មិនមែន មកពីសង្គមខ្មែរ ខ្វះ ទស្សនវិជ្ជា ឬ ជា កំហុស របស់ ពុទ្ធសាសនា នោះឡើយ ព្រោះថា ប្រទេស ថៃ សង្គម របស់គេ មាន ធម្មជាតិ ប្រហាក់ប្រហែលនឹង សង្គមខ្មែរ ដែរ តែ គេ មាន ការរីកចំរើន បាន ព្រោះ ប្រទេស ថៃ មាន អ្នកដឹកនាំ មាន បញ្ញាពន្លឺ (dirigeants éclairés) ទុក ប្រយោជន៍ ជាតិ ជា ចលករ នៃ អភិវឌ្ឍន៍ ប្រជាជាតិថៃ។ ត្រូវដឹងថា នៅក្នុង សតវត្សទី១៤ នេះឯង ដែល អ្នកដឹងនាំខ្មែរយើង ប្តូរ សាសនា ជាតិ ពី ព្រហ្មញ្ញសាសនា មក ពុទ្ធសាសនា ប្រហែល មានគោលបំណង រកដំណោះស្រាយ នូវ វិបត្តិ គ្រប់បែបយ៉ាង ដែល ប្រជាជាតិខ្មែរ បាន ជួបប្រទះ នោះឯង។ នៅពេលនោះ អ្នកដឹកនាំខ្មែរ យល់ឃើញ ថា ពុទ្ធសាសនា អាច ជា ចម្លើយមួយបាន ព្រោះ អាចរកឃើញ សិនិទ្ធពល រវាង អ្នកដឹកនាំ នឹង ប្រជារាស្ត្រ ដែល ជា ពុទ្ធបរិស័ទ។ ការរក ភាពនៅជិតគ្នា រវាង អ្នកដឹងនាំ នឹង ប្រជារាស្ត្រ នេះ មិន ហុច លទ្ធផល ជាវិជ្ជមាន ណាស់ណា នោះឡើយ ព្រោះ អ្នកដឹកនាំ ជាតិ មិនបានធ្វើ វិសោធនកម្ម របៀបដឹងនាំជាតិ ជាជម្រៅ នោះទេ គឺថា គ្រាន់តែ យក ពុទ្ធសាសនា សំរាប់ ធ្វើ ជា ខែល ការពារ បុព្វសិទ្ធិ ខ្លួន ជា អ្នកដឹកនាំ នៅក្នុង ជំនឿ កម្មផល «អ្នកដឹកនាំ ជា អ្នកមាន បុណ្យ» ជំនួយ ជំនឿ «អ្នកដឹកនាំ ជា អាទិទេព» ដែល ខ្លួន ទុក ជា សម្មតសច្ច (vérité conventionnelle) សំរាប់ របបដឹកនាំថ្មី។ នៅត្រង់ចំណុចនេះឯង ដែល ខ្មែរខ្លះ យល់ ឃើញថា កង្វះ ទស្សនវិជ្ជា នៅស្រុកខ្មែរ ដែល ជា ពន្លឺបញ្ញា មាន នៅក្នុង សតវត្ស ទី១៧ នៅ បស្ចឹមប្រទេស ជា កត្តាមួយ នាំឲ សង្គមខ្មែរ គ្មានការរីកចំរើន ក្នុងផ្នែក បញ្ញា។ តាមពិត គំនិត បែបនេះ គ្រាន់តែជា គោលនិយម នៃ គំនិត ពួកអ្នកឆ្វេងនិយមខ្មែរ ចម្លងពី គំនិតបដិវត្តន៍ មានកើតឡើង នៅ ទ្វីបអ៊ឺរុប និង នៅ ប្រទេស រ៉ុស្ស៊ី ក្នុង សតវត្ស ទី១៩ និង ទី២០ ដែល ទុក របប ដឹកនាំ អភិរក្សនិយម មាន ជា អាទិ របប រាជាធិបតេយ្យនិយម សក្តិភូមិ ជំនឿ សាសនា ប្រពៃណី ទំនៀមជាតិ ជា សត្រូវនឹង គំនិតបដិវត្តន៍ ដែល សំអាង លើ វិសិដ្ឋ

ភាព នៃវិធី វិទ្យាសាស្ត្រ ដែលមាន ចែង នៅក្នុង ទ្រឹស្តី របស់ លោក Karl Marx ដែល គេ ទុកជា បិតា នៃ សង្គមនិយម និង កុម្មុយនិស្តនិយម។ ចំពោះ អ្នកឆ្វេងនិយមខ្មែរ កង្វះ ទស្សវិជ្ជា មាន ទ្វេអនុភាព ជាអវិជ្ជមាន ដល់ សង្គមខ្មែរ គឺ នាំឲ ក្រិន បញ្ញា ផង និង អវត្តមាន នៃ វិទ្យាសាស្ត្រ ផង ដែល ជា ទ្វេកត្តា សំរាប់ ធ្វើ អភិវឌ្ឍន៍ សង្គម គ្រប់ផ្នែក ដើម្បី សុភមង្គល និង សុខុមាលភាព នៃ ប្រជាពលរដ្ឋ។ តែ យើងដឹង ថា គំនិត នេះ គឺ គ្រាន់តែ ជា ការស្រម័យហួសហេតុ ព្រោះ ទស្សនវិជ្ជា ក្តី វិទ្យាសាស្ត្រ ក្តី មិនមែន ជា ឪសថ ដាច់មុខ សំរាប់ ព្យាបាល ជំងឺ សង្គមចាស់ ឲជា ទាំងស្រុង បាន នោះឡើយ បើ ឪសថ នោះ វា មិន សម្របនឹង ធម្មជាតិ នៃ សរីរៈ នៃ សង្គម ឧបមា ដូចយក ត្រី ឲមក រស់នៅ លើគោក ឬ យក មនុស្ស មិនចេះហែលទឹក ឲហែល ឆ្លងស្ទឹង នោះឯង។ ឪសថ បែបនេះ ទុកណា ជា ឪសថ បង្កើតឡើង ដោយ អ្នកប្រាជ្ញ ល្បីល្បាញ ក៍ដោយ ក៍ វា មិនអាច ព្យាបាល អ្នកជំងឺ បាននោះឡើយ។

---

## លទ្ធិប្រជាធិបតេយ្យ

---

លទ្ធិប្រជាធិបតេយ្យ មិនមែន ជា ក្បួតសាកល ដែល គេ អាចយក វា មក អនុវត្ត ទាំង គម្រូល បាននោះឡើយ ដូចគ្នានឹង ទ្រឹស្តី បដិវត្តន៍ កុម្មុយនិស្ត នោះដែរ ព្រោះនៅ ក្នុងសង្គម និមួយៗ វាមាន ការវិវន្តន៍ ផ្ទាល់ របស់វា។ ប្រើ អំពើ ឃោឃៅ ដើម្បី ប្តូរ ធម្មជាតិដើម និង លទ្ធវត្ថុ (chose acquise) រាប់ពាន់ឆ្នាំ តាម ការវិវត្តន៍ ជាធម្មតា របស់ វា គឺ ច្បាស់ជាដើរ ទៅ រក បរាជ័យ ដាច់ ខាត។ បដិវត្តន៍ កុម្មុយនិស្ត មាន នៅ ក្នុងលោក នេះ ជាឧទាហរណ៍ ស្រាប់ សំរាប់ បង្ហាញ នូវ វិនាដកម្ម នៃ មនុស្សជាតិ កើត អំពី អំពើ ឃោឃៅ កុម្មុយនិស្តនិយម ដែល នាំឲ មនុស្ស ស្លាប់ ជាង ១០០ លាននាក់ នៅក្នុង សតវត្សទី២០។ បដិវត្តន៍ ហិង្សា នេះ គឺ ពួកកុម្មុយនិស្ត ធ្វើឡើង ក្នុងនាម លទ្ធិប្រជាធិបតេយ្យ បរិសុទ្ធ នៅក្នុងគោលដៅ ជាទីបញ្ចប់ គឺបង្កើត សង្គមគ្មានវណ្ណៈ ដែល យក កម្លាំង កម្មាជីព (force prolétaire) ជា កម្លាំង ឈានមុខ នៅក្រោម ការដឹងនាំ របស់ បក្សកុម្មុយនិស្ត ដែល ជា អង្គការ តែមួយគត់ ស្គាល់ នូវ ការពិត អំពី ការប្តូរ ធម្មជាតិ នៃ សង្គម តាម វិធី វិទ្យាសាស្ត្រ ឲក្លាយបាន ជាសង្គម សុក្រិត សំរាប់ មនុស្ស លោក។ ការស្វែងរក សេចក្តីបរិសុទ្ធ នៃ បដិវត្តន៍ នេះឯងហើយ ដែលជា គំនិតមមៃ របស់ លទ្ធិកុម្មុយនិស្ត ដែលជា គំនិតមួយ ផ្ទុយនឹង សេចក្តីបរិសុទ្ធ នៃ ធម្មជាតិ ព្រោះ វា ជា សេចក្តីបរិសុទ្ធ សិប្បនិម្មិត បង្ខំ មនុស្ស ឲ អនុវត្ត មាគ៌ា របស់បក្ស ក្នុង អារម្មណ៍ បំបាត់ចោល ឲអស់រលីង នូវ កម្មសិទ្ធ ខាង បញ្ញា របស់ មនុស្ស គឺ មនុស្ស ត្រូវ រស់ដូច ជា មនុស្សយន្ត ឬ ជា សត្វពាហនៈ បំរើ បក្ស ក្នុង គោលជំហរ និង សតិអារម្មណ៍ ស្មោះ

ត្រង់ ជាមួយ បក្ស និង អនុវត្ត មាគ៌ា របស់ បក្ស ទើប បាន ផ្ទួរផង់ ជា និច្ច ទើប មនុស្ស អាច ក្លាយ ជា ជនកុម្មុយនិស្ត បាន។ ការណ៍ នេះឯង ហើយ ដែល ជា គំនិត មមៃស្លាប់ (utopie meurtrière) នៃ លទ្ធិកុម្មុយនិស្ត។

លទ្ធិ ប្រជាធិបតេយ្យ សេរី វា ខុសគ្នាពី លទ្ធិ ប្រជាធិបតេយ្យ កុម្មុយនិស្ត ព្រោះ លទ្ធិ សេរី ទុក មនុស្ស ជា គោលដៅ ចុងក្រោយ របស់ លទ្ធិ គឺថា អ្វីៗ ដែល ត្រូវ ធ្វើ គឺ ធ្វើ ឡើង ដើម្បី បំរើ ប្រយោជន៍ មនុស្ស ព្រោះ មនុស្ស នេះឯង ដែលជា នាដការសកម្ម នូវ គ្រប់ សកម្មភាព របស់ខ្លួន ព្រោះ មនុស្ស ជា កម្មសិទ្ធ ខាង បញ្ញា ដែល ជា តម្លៃ សជ្ឈន្តិកៈ (intrinsèque) នៃ មនុស្សលោក ព្រោះ មនុស្ស ជា សេរីជន។ ប្រតិស្ឋ (fonder) ទ្រឹស្តី អ្វីមួយ សំរាប់ បំបាត់ចោល ឲអស់រលីង នូវ សេរីភាព បុគ្គល គឺដូចជា ប្រដូចមនុស្ស ទៅនឹង វត្ថុធាតុ គ្មាន វិញ្ញាណ គឺ ជា ទស្សនៈ នៃ បដិវាទកម្ម (concept de contradiction) នឹងច្បាប់ធម្មជាតិ ព្រោះ សេរីភាព នៃ មនុស្ស នេះឯង ជា ចលករ (moteur) នូវ សេចក្តី ចំរើនលូតលាស់ ដែល មាន ប្រវត្តិសាស្ត្រ នៃ មនុស្សជាតិ ជា សាក្សី។ ពី យុគ មួយ ទៅ យុគ មួយ សេរីជន ជា ស្ថាបនិក នៃ អារ្យធម៌ កើតចេញ ពី គ្រឹះ ធម្មជាតិ បី យ៉ាងៈ សរលភាព (simplicité) វិស្សាសភាព (sincérité) និង គតិយុត្តិធម៌ (droiture)។ បច្ច័យ ទាំង បី នេះ ឯងហើយ ជា មូលដ្ឋាន នៃ វប្បធម៌ នៃ មនុស្សជាតិ ដែល អាចនាំ ឲប្តូរ ពី របប សក្តិភូមិ, អត្តាវសិនិយម (despotique) មកដល់ របប លទ្ធិ ប្រជាធិបតេយ្យសេរី ហើយ កត្តា ដែល សំរេច នូវ ព្រឹត្តិការណ៍ នេះ គឺ សេរីភាព នោះឯង។ អាស្រ័យហេតុនេះ គេ អាច ទុក វិជយៈ (triomphe) នៃ លទ្ធិប្រជាធិបតេយ្យសេរី ជា អំពើធ្វើល្អ សំរាប់ មនុស្សជាតិ ហើយ មានតែមួយគត់ នៅក្នុងលោក។ ម្យ៉ាងមួយទៀត វិជយៈ នេះ ជា ការបញ្ចប់ នូវ គំនិត មមៃស្លាប់ នៃ លទ្ធិកុម្មុយនិស្ត ដែល លោក Francis Fukuyama ហៅ ថា «ទីបញ្ចប់ នៃ ប្រវត្តិសាស្ត្រ»។ ទោះបីគេឃើញមាន កើត នា បច្ចុប្បន្ន នេះ នូវ ព្រឹត្តិការណ៍ ភេរវកម្ម នៅក្នុងពិភពលោក តែ ព្រឹត្តិការណ៍ នេះ ពុំ អាច នឹង ឈ្នះ លទ្ធិប្រជាធិបតេយ្យសេរី បាន នោះឡើយ ព្រោះ អំពើ ភេរវកម្ម ក៏ដូច លទ្ធិកុម្មុយនិស្ត សុទ្ធជា អំពើ លុប បំបាត់ សេរីភាព។ ត្រូវដឹងថា លទ្ធិប្រជាធិបតេយ្យសេរី ជា របប តែមួយគត់ ដែល បង្កើត ឲមាន រដ្ឋាភិបាល នៃ ប្រជាជន ដោយ ប្រជាជន និង ដើម្បី ប្រជាជន ដែល ជា របប លុបបំបាត់ នូវ លក្ខណសម្បត្តិ នៃ ប្រជាពលរដ្ឋ ជា រាស្ត្រ (sujet) របស់ ព្រះមហាក្សត្រ ឬ ខ្ញុំស្តេច និង ជា ប្រជាពលរដ្ឋ គ្រាន់តែ ជា អ្នកអនុវត្តច្បាប់ ដែល បង្កើតឡើង ដោយ អ្នកដឹកនាំ។ ការលុបបំបាត់នេះ គឺ ដើម្បី បង្កើត របប ដែលទុក ប្រជាពលរដ្ឋ ជា ម្ចាស់ នៃ អំណាចដឹកនាំ។ លទ្ធិប្រជាធិបតេយ្យសេរី នេះហើយ ជា មហាជំហាន នៃ ការរីកចំរើន នៃ មនុស្សជាតិ។

# លទ្ធិប្រជាធិបតេយ្យ នៅ ស្រុកខ្មែរ

ចាប់ ពី ឆ្នាំ ១៩៤៦ នៅ ស្រុកខ្មែរ គេឃើញ ចាប់ផ្តើម មាន គំនិត លទ្ធិប្រជាធិបតេយ្យសេរី ដែលនាំ បង្កើត ឲមាន រដ្ឋធម្មនុញ្ញ នាឆ្នាំ ១៩៤៧។ តែ កំណើតនេះ មាន ការ វែក រវាង សកម្មភាព និង ចេតនា របស់ អ្នកប្រជាធិបតេយ្យនិយម ជាពិសេស ពួកអ្នកអភិរក្សនិយម នៅក្នុង សម័យនោះ គឺថា មាន ចេតនា ចង់ឲមាន លទ្ធិប្រជាធិបតេយ្យសេរី តែ នាំគ្នា ធ្វើ សកម្មភាព គ្រប់ បែបយ៉ាង ដើម្បី រំលស់ (étouffer) វា កុំឲលទ្ធិ នេះ ប៉ះពាល់ ដល់ បុព្វសិទ្ធិ របស់ខ្លួន។ ការណ៍ នេះ ជា ឧបសគ្គ ដ៏សំខាន់មួយ ដល់ ដំណើរ ធម្មតា នៃ លទ្ធិប្រជាធិបតេយ្យសេរី។ កំណើត របប សង្គមរាស្ត្រនិយម ក្នុង ឆ្នាំ ១៩៥៥ ទុកជា ការបង្ហើយអោយស្លាប់ (coup de grâce) នៃ របប លទ្ធិប្រជាធិបតេយ្យសេរី នៅ ស្រុកខ្មែរ ព្រោះ របប សង្គមរាស្ត្រនិយម ជា របប រាជានិយមផ្តាច់ការ មាន ប្រមុខរដ្ឋ ពីរ រូប ៖ ព្រះមហាក្សត្រ មាន តួនាទី ជា តំណាង ប្រពៃណីជាតិ និង ព្រះប្រមុខរដ្ឋ អស់មួយជីវិត ជា អ្នកដឹកនាំ ប្រជាជាតិ។ ព្រឹត្តិការណ៍ ថ្ងៃ ទី ១៨ មិនា ឆ្នាំ ១៩៧០ កើត ឡើង ពី ប្រតិកម្ម ប្រជាពលរដ្ឋខ្មែរ ប្រឆាំងនឹង វត្តមាន កងទ័ព យៀកកុង មកតាំងទី នៅក្នុង ស្រុកខ្មែរ ហើយ នាំគ្នា តម្រូវ ឲ រដ្ឋសភាជាតិ ដោះស្រាយ បញ្ហា នេះ ជា បន្ទាន់។ តែ ដោយសារ វត្តមាន ទ័ពយៀកកុង មាន ពាក់ព័ន្ធ ដោយ ចំពោះនឹង នយោបាយ សម្តេច សីហនុ ដែល ជា ប្រមុខរដ្ឋ នៅជំនាន់នោះ នាំ បង្កើត វិវាទ នយោបាយ រវាង រាជរដ្ឋាភិបាល នឹង ព្រះអង្គ។ ទោះបី រាជរដ្ឋាភិបាល ខំ ស្វែងរក គ្រប់មធ្យោបាយ ដើម្បី ដោះស្រាយ អធិករណ៍ នេះ ដើម្បី រក ឯកភាពជាតិ នៅចំពោះ មុខ ការឈ្លានពាន បូរណភាព ទឹកដីខ្មែរ ពី សំណាក់ បរទេស តែ សម្តេច សីហនុ ដែល កំពុង សំរាកកាយ នៅ ប្រទេស បារាំង បាន បដិសេធ ជួបនឹង ប្រតិភូ ដែល មាតា ព្រះអង្គ បញ្ជូន ឲមកជួប ព្រះអង្គ ដើម្បី ថ្វាយ ដំណឹងពិត អំពី ស្ថានការណ៍ នៅក្នុង ប្រទេស មិនតែប៉ុណ្ណោះ ព្រះអង្គ បាន ចោទប្រកាន់ ដល់ រាជរដ្ឋាភិបាល ថា ក្បត់ ព្រះអង្គ។ ស្ថានភាពទ័លច្រក នេះ នាំឲ សភាជាតិ បាន សំរេចចិត្ត បោះឆ្នោត ទំលាក់ សម្តេច សីហនុ ពីដំណែង ប្រមុខរដ្ឋ ដោយទុក ប្រយោជន៍ជាតិ ជា ធំ ។ ប្រតិកម្ម អវិជ្ជមាន របស់សម្តេច សីហនុ បង្កើត រាជរដ្ឋភិបាល រួបរួមជាតិខ្មែរ នៅ ប្រទេស ចិន ប្រជាមានិត រួចស្នើរ ឲទ័ព បរទេស វាយប្រហារ កងទ័ពជាតិ នៅក្នុង ទឹកដីខ្មែរ រុញឲ រដ្ឋាភិបាល ស្របច្បាប់ ប្រកាស របប សាធារណរដ្ឋ ក្នុង គោលបំណង ប្រត្យាស្ថាបនា លទ្ធិប្រជាធិបតេយ្យសេរី ដែល ជា មាគ៌ា មួយគត់ អាច បង្កើត កម្លាំងជាតិ ដើម្បីតស៊ូរំដោះ ទឹកដីខ្មែរ ដោយប្រជាពលរដ្ឋ ដើម្បី ប្រជាពលរដ្ឋ។ តែ សង្គ្រាម នាំ រំខាន ដល់ ដំណើរ លទ្ធិប្រជាធិបតេយ្យសេរី ព្រោះ ប្រជាជាតិខ្មែរ ត្រូវ ចាំបាច់ រស់ នៅក្នុង ភាព

អាសន្ន ដើម្បី ធ្វើ សង្គ្រាម តស៊ូ ប្រឆាំងនឹង សត្រូវជាតិ។ ដូច្នេះ គេ អាច សន្និដ្ឋាន បាន ថា បំណង ប្រត្យាស្ថាបនា លទ្ធិប្រជាធិបតេយ្យសេរី របស់ របប សាធារណរដ្ឋ ជា បំណង អភូត (intention non réalisée)។ តែ ប្រជាពលរដ្ឋខ្មែរ ទុក ជ័យជំនះ ពួកខ្មែរ កុម្មុយនិស្ត ឬ ខ្មែរក្រហម ជា មហាភ័យ ដល់ ប្រជាជាតិខ្មែរ ព្រោះ បក្សកុម្មុយនិស្ត យក ជ័យជំនះខ្លួន ដើម្បី ធ្វើ បដិវត្តន៍ ហិង្សា សម្លាប់ខ្មែរ ដើម្បី កសាង បក្ស មហាលោតផ្លោះ នាំឲ ប្រជាជាតិខ្មែរបាត់ កម្លាំងជាតិ មានតែ កម្លាំងបក្ស ដែលជា កម្លាំងសង្កត់សង្កិន ទៅលើ ប្រជាជន ដើម្បី កសាង កម្ពុជាថ្មី នៅក្នុង ការមមៃស្លាប់ មួយ។ របប កម្ពុជា ប្រជាធិបតេយ្យ មានឈ្មោះ តែ ប្រជាធិបតេយ្យ តែ វា ជា លទ្ធិ ក្លែងក្លាយ ជា របប បដិវត្តន៍ ជានិច្ច គ្មានសម្ពភាព បង្កើត រដ្ឋាភិបាលជាតិ ដើម្បី ដឹកនាំ ប្រជាជាតិ ដែលនាំ បំបែក ឯកភាពជាតិ។ នៅក្រោម អង្គការ អាថកំបាំង ហៅ «អង្គការលើ» កម្ពុជា ប្រជាធិបតេយ្យ គ្រាន់តែ ជា អំបែង ក្រុមជាច្រើន យកវាមកផ្គុំ ធ្វើជា អង្គការលើរួម តែ កំទេច និមួយៗ រស់នៅក្នុង អនាធិបតេយ្យ អនុវត្ត ភេរវកម្ម ដើម្បី ការពារ ប្រយោជន៍ក្រុមរៀងៗខ្លួន។ អ្វី ដែលនឹង កើតឡើង ពី កង្វះ សម្ពភាព នៃ ពួក អ្នកដឹកនាំ ខ្មែរក្រហម វាមាន កើត ឡើង ពិត នៅ ថ្ងៃទី ៧ មករា ឆ្នាំ ១៩៧៩ គឺ របប កម្ពុជា ប្រជាធិបតេយ្យ គ្មានលទ្ធភាព ការពារ បូរណភាពទឹកដី និង អធិបតេយ្យភាព ជាតិ នៅ ចំពោះមុខ ការវាយប្រហារ ពី សំណាក់ កងទ័ព យៀកណាម ចូល កាន់កាប់ ស្រុកខ្មែរ បាន យ៉ាងងាយបំផុត ហើយ ប្រកាស រំដោះ ប្រជាជនខ្មែរ ពី របប ប្រល័យពូជសាសន៍ខ្លួនឯង។ សេរីការ (libération) នេះ ជា ព្រហ្មលិខិត របស់ ប្រជាជនខ្មែរ ព្រោះ យៀកណាម ឆ្លៀតយក ឪកាសនេះ ដើម្បី ធ្វើ សមិទ្ធិកម្ម នូវ មហិច្ឆិតា ពាន់ឆ្នាំ របស់ខ្លួន គឺ បញ្ចូល ស្រុកខ្មែរ ទៅក្នុង សហព័ន្ធ ឥណ្ឌូចិន ដែល មាន យៀកណាម ជា អ្នកត្រួតត្រា ក្នុង ឋានៈ ជា អ្នករំដោះ និង សង្គ្រោះ ប្រជាជនខ្មែរ។ ការណ៍ នេះ ត្រូវ សហគមអន្តរជាតិ ផ្តន្ទាទោស តាមរយៈ ក្រុមព្រឹក្សាសន្តិសុខ នៃ អង្គការសហប្រជាជាតិ មិនទទួលស្គាល់ រដ្ឋាភិបាលបន្តុបឡើង ដោយ កងទ័ព យៀកណាម នៅ ភ្នំពេញ ហើយ នៅតែទុក រដ្ឋាភិបាល របប កម្ពុជា ប្រជាធិបតេយ្យ ជា រដ្ឋាភិបាល ស្របច្បាប់ខ្មែរ និង អន្តរជាតិ។ ស្ថានភាពថ្មីនេះ នាំឲ ប្រជាជនខ្មែរ បន្ត រស់ អស់រយៈ ពេលដប់ឆ្នាំ ក្នុង សង្គ្រាម ឥតច្រកចេញ រវាង ទ័ពយៀកណាម ឈ្លានពាន គាំទ្រ ដោយ សហភាព សូវៀត និង ប្រទេស រណប ជាមួយនឹងរបប កម្ពុជា ប្រជាធិបតេយ្យ និង ចលនា តស៊ូខ្មែរ គាំទ្រ ដោយ ចិនប្រជាមានិត និង សមាគម នៃ ប្រទេស អាស៊ី ភាគអគ្នេយ៍ (ASEAN)។ សង្គ្រាម នេះ ជា សង្គ្រាម គ្មាន ប្រជាជន គាំទ្រ ព្រោះ វា ជា សង្គ្រាម បំរើ ប្រយោជន៍ យុទ្ធការី ដែល មាន លោក កុម្មុយនិស្ត ចិន និង សហភាព សូវៀត ជា អ្នកផ្តល់ជំនួយសំខាន់ ដល់ គូវិវាទ ទាំងសងខាងដែល គេ អាច ទុក វាជា ការបន្ត សង្គ្រាម ត្រជាក់ រវាង ចិនកុម្មុយនិស្ត ជាមួយនឹង សហភាពសូវៀត នៅស្រុក

ខ្មែរ។ កិច្ចព្រមព្រៀង សន្តិភាព នៅ ទីក្រុង បារីស នា ថ្ងៃទី ២៣ តុលា ឆ្នាំ ១៩៩១ ក្រោម អំណាច អង្គការ សហប្រជាជាតិ (អ.ស.ប.) ឲ សេចក្តីសង្ឃឹម មួយ ដល់ ប្រជាជនខ្មែរ រួចចេញ ពី ការកាន់កាប់ កងទ័ពយៀកណាម ពី សង្គ្រាម រវាង យុទ្ធការីខ្មែរ ដែល ជា មូលដ្ឋាន នៃ សន្តិភាព ដើម្បី អាច កសាង លទ្ធិប្រជាធិបតេយ្យសេរី នៅស្រុកខ្មែរ។ ការ ប្រើ មធ្យោបាយ ដ៏ សម្បើម នៃ អ.ស.ប. សំរាប់ បនុស្ថាបនា (ការស្ថាបនាឡើងវិញ) ស្រុកខ្មែរ ក្រោយ ពី បាន ជួបប្រទះ នូវ មហាភ័យ តាំង ពី ឆ្នាំ ១៩៧០ ជា ព្យាក្រឹតិ (démonstration) នៃ ឆន្ទៈ របស់ អ.ស.ប. ដើម្បីធ្វើ អោយ សំរេច ជា ដាច់ខាតនូវ គោលបំណង នៃ កិច្ចព្រមព្រៀង សន្តិភាព នៅ ស្រុកខ្មែរ តែគ្រប់ នាដការខ្មែរ ជា អ្នក បំផ្លាញ ដោយ ខ្លួនឯង ដោយ ចេតនា ក្តី អចេតនា ក្តី ដើម្បី រក ប្រយោជន៍ក្រុមបក្ស ដែល នាំ អោយ យៀកណាម ឆ្លៀត បន្ត ប្រើ យុទ្ធសាស្ត្រ បំបែកខ្មែរ ដើម្បី បន្ត ត្រួតត្រា ខ្មែរ ជានិច្ច ទោះបី មាន កិច្ចព្រមព្រៀង សន្តិភាព ក៏ដោយ។ ការណ៍នេះ ជា ឧបសគ្គ សំខាន់មួយ សំរាប់ ដាំ លទ្ធិប្រជាធិបតេយ្យសេរី នៅ ស្រុកខ្មែរ។

យើងឃើញថា ការបំបាត់ចោល នូវ លទ្ធិប្រជាធិបតេយ្យសេរី តាំង ពី ឆ្នាំ ១៩៥៥ មក ប្រជាពលរដ្ឋខ្មែរ រស់ ជា និច្ច នៅក្នុង របប ផ្តាច់ការ ឬ ក្នុង សង្គ្រាម ដែល នាំ អោ យ ប្រជាពលរដ្ឋខ្មែរ បង្អត់ នូវ សិទ្ធិពលរដ្ឋ ហើយ ស្គាល់តែ ករណីកិច្ច ជា រាស្ត្រ សំរាប់ តែ គោរពច្បាប់ របស់ អ្នកដឹកនាំ តែប៉ុណ្ណោះ។ មាគ៌ា តែ មួយគត់ ដែល អាច អោយ ស្រុក ខ្មែរ ចេញផុត គ្រប់បញ្ហា ដែលខ្លួនកំពុង ជួបប្រទះ គឺ ចាំបាច់ ដាំ ឲដុះ ជា ដាច់ខាត នូវ លទ្ធិប្រជាធិបតេយ្យសេរី ដែល មាន ប្រជាពលរដ្ឋ ជា ម្ចាស់ នៃ អំណាចរដ្ឋ ជា ពលរដ្ឋ ទទួល ការខុសត្រូវ លើ ជោគ វាសនា របស់ខ្លួន។ ពុំនោះសោត ស្រុកខ្មែរ នឹង ក្លាយ ជាប្រទេស រណប នៃ ប្រទេសយួន ឬ ជា កម្ពុជាក្រោម នោះជាពុំខាន ដែល ខ្មែរ យើង តែងតែ មាន ការបារម្ភ ជានិច្ច។ មកដល់ បច្ចុប្បន្នកាល ការបារម្ភ នេះ កំពុង ក្លាយ ជា ការពិតមួយ សំរាប់ ប្រជាជាតិខ្មែរ៕